
For maximum power
and performance
PGO
PURE GOLD OIL
ពតីមានទិន្នន័យបច្ចេកទេស



ព្យួរហ្គោល គឺជាក្រុមហ៊ុនឈានមុខគេមួយនៅក្នុងវិស័យប្រេងដោយមានចក្ខុវិស័យក្លាយជាក្រុមហ៊ុនថាមពលពហុជាតិសាសន៍ដែលមានប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងជំរុញកំណើនអន្តរជាតិតាមរយៈគម្រោងអភិវឌ្ឍន៍ដ៏ល្អប្រសើរជាច្រើនដែលគ្របដណ្តប់លើទ្វីបផ្សេងៗគ្នា។ បន្ទាប់ពីបានដាក់ឱ្យដំណើរការរោងចក្រចម្រាញ់ប្រេងនៅក្នុងតំបន់សេដ្ឋកិច្ចសេរីHamriyahនៃទីក្រុងSharjahអស់រយៈពេលប៉ុន្មានឆ្នាំមកនេះ បច្ចុប្បន្នព្យួរហ្គោលបានក្លាយជាក្រុមហ៊ុនដែលមានអង្គភាពអាជីវកម្មយុទ្ធសាស្ត្រចំនួន៦ដែលមានមូលដ្ឋានរឹងមាំរួមមាន៖ ការជួញដូរនិងការផ្គត់ផ្គង់ប្រេងឥន្ធនៈដល់នាវា(Bunkering)ការចម្រាញ់ប្រេងការផលិតខាញ់(Grease)ប្រេងរំអិលនិងប្រេងសម្រាប់ត្រង់ស្វូ(Transformer Oils) ស្ថានីយស្តុកប្រេងការផលិតប៊ីទូមែន(Bitumen)និងសេវាកម្មដឹកជញ្ជូន និងភស្តុភារកម្ម។ អង្គភាពអាជីវកម្មទាំងអស់នេះគាំទ្រគ្នាទៅវិញទៅមកដែលធ្វើឱ្យព្យួរហ្គោក្លាយជាក្រុមហ៊ុនចម្រុះដែលមានប្រតិបត្តិការប្រទាក់ក្រឡាគ្នាយ៉ាងល្អប្រសើរ។

ព្យូរហ្គោលគឺជាក្រុមហ៊ុនផលិតឈានមុខគេនូវប្រេងរំអិលគ្រប់ប្រភេទដូចជាប្រេងរំអិលសម្រាប់យានយន្ត ឧស្សាហកម្មនិងវិស័យនាវាចរណ៍។ ជាមួយនឹងរោងចក្រលាយប្រេងដ៏ទំនើបដែលបំពាក់ដោយឧបករណ៍ផលិតនិង ឧបករណ៍មន្ទីរពិសោធន៍ចុងក្រោយបំផុតដើម្បីផលិតប្រេងរំអិលដែលមានគុណភាពខ្ពស់ព្យូរហ្គោលក៏ចូលរួមក្នុការ ជួញដូរសារធាតុបន្ថែម(additives)សម្រាប់ប្រេងរំអិលនិងផលិតប្រេងរំអិលព្រមទាំងប្រេងមូលដ្ឋាន (Base Oils) សម្រាប់យានយន្ត នាវាចរណ៍ និងឧស្សាហកម្មផងដែរ។ ផលិតផលទាំងអស់នេះឆ្លងកាត់ការត្រួតពិនិត្យគុណ ភាពយ៉ាងតឹងរ៉ឹងបំផុត។ ផលិតផលដែលមានគុណភាព និងភាពចម្រុះរបស់ក្រុមហ៊ុន រួមមានប្រេងរំអិលប្រភេទ សំយោគ(synthetic)ដែលមានប្រសិទ្ធភាពខ្ពស់បំផុត ដោយផ្តល់នូវការការពារដ៏ល្អឥតខ្ចោះអាយុកាលប្រើប្រាស់ បានយូរ និង ប្រសិទ្ធភាពខ្ពស់។

ប្រភេទផលិតផលរបស់យើង

យានយន្ត (AUTOMOTIVE)

ផលិតឡើងពីប្រេងមូលដ្ឋាន(Base stocks) ដែលបានចម្រាញ់យ៉ាងល្អិតល្អន់ និងសារធាតុបន្ថែមដែលបានជ្រើសរើសយ៉ាងពិសេសដើម្បីបំពេញតាមលក្ខណៈពិសេស និងកម្រិតនៃប្រសិទ្ធភាព។

- ប្រេងរំអិលសម្រាប់រថយន្តដឹកអ្នកដំណើរ
- ប្រេងម៉ាស៊ីនម៉ាស៊ូតសម្រាប់យានយន្តធុនធ្ងន់
- ប្រេងម៉ាស៊ីនសម្រាប់ម៉ាស៊ីនប្រភេទ ២ ហ្សុក (two-stroke)
- ប្រេងម៉ាស៊ូតសម្រាប់រថភ្លើង
- ប្រេងសម្រាប់ប្រព័ន្ធបញ្ជូនកម្លាំង (Drive line)
- ទឹកត្រជាក់សម្រាប់ម៉ាស៊ីន (Coolants)

- ប្រេង ATF Dexron II, III

- ប្រេងហ្វ្រាំង Dot-3 និង Dot-4

ឧស្សាហកម្ម (INDUSTRIAL)

គុណភាពខ្ពស់ពិសេសសម្រាប់អាយុកាលប្រេងប្រើប្រាស់បានយូរ ដំណើរការរលូន និងមានស្ថេរភាព កម្តៅដ៏ល្អឥតខ្ចោះនៅសីតុណ្ហភាពខ្ពស់ខ្លាំង។

- ប្រេងអ៊ីដ្រូលីក (Hydraulic oils)

- ប្រេងសម្រាប់ប្រអប់លេខឧស្សាហកម្ម

- ប្រេងសម្រាប់ទួរប៊ីន

- ប្រេងសម្រាប់ម៉ាស៊ីនបង្ហាប់ខ្យល់ (Compressor oils)

- ប្រេងសម្រាប់ទ្រនាប់ (Bearing) និងប្រព័ន្ធចរន្តប្រេង (Circulating oils)

- ប្រេងសម្រាប់ឧស្សាហកម្មវាយនភណ្ឌ

- ប្រេងផ្ទេរកម្តៅ (Heat transfer oil)

- ប្រេងសម្រាប់ម៉ាស៊ីនផលិតកម្ម (Machine tool oils)

- សារធាតុរាវសម្រាប់ដំណើរការកែច្នៃលោហៈ

នាវាចរណ៍ (MARINE)

- ប្រសិទ្ធភាពខ្ពស់ផ្តល់នូវការរំអិលដ៏ល្អឥតខ្ចោះនិងជួយការពារការកកើតនៃកាកសំណល់នៅក្នុងបន្ទប់ចំហោះ

- ប្រេងសម្រាប់ម៉ាស៊ីនក្រៅទូក (outboard) ប្រភេទ ២ ហ្សុក

- ប្រេងម៉ាស្ទ័តសម្រាប់ម៉ាស៊ីនប្រភេទ trunk piston ដែលមានល្បឿនមធ្យម

ប្រេងម៉ាស៊ីនគុណភាពខ្ពស់ប្រភេទ Mono-grade

កម្រិត (GRADE)

SAE 30, 40, 50

ការណែនាំ

ប្រេងម៉ាស៊ីនលេខ 30, 40 និង 50 ត្រូវបានផលិតឡើងពីប្រេងមូលដ្ឋាន (Base stocks) ដែលបានចម្រាញ់យ៉ាងល្អិតល្អន់ និងមានសន្ទស្សន៍ viscosity ខ្ពស់ ព្រមទាំងមានសារធាតុបន្ថែមដែលផ្តល់នូវលក្ខណៈសម្បត្តិក្នុងការសម្អាត (detergent) ការបំបែកភាគល្អិតកខ្វក់ (dispersant) ការការពារការកត់ស៊ី (anti-oxidant) និងការការពារការសឹក (anti-wear)។

ការប្រើប្រាស់

ត្រូវបានណែនាំឱ្យប្រើជាប្រេងសម្រាប់ប្រព័ន្ធម៉ាស៊ីន (crankcase) នៃម៉ាស៊ីនសាំង 4 វគ្គ (four-stroke) សេរីចាស់ ម៉ាស៊ីនម៉ាស៊ូតប្រភេទស្តានី (ដូចជា ម៉ាស៊ីនបូមទឹក និងម៉ាស៊ីនភ្លើង) និងម៉ាស៊ីនម៉ាស៊ូតសម្រាប់យានយន្តសេរីចាស់ ជាពិសេសសម្រាប់ការប្រើប្រាស់ក្នុងកងយានយន្តពាណិជ្ជកម្ម។

កម្រិតសមត្ថភាព និងអត្ថប្រយោជន៍

បំពេញតាមកម្រិតសមត្ថភាពនៃស្តង់ដារ៖ API CC, CC/SC, CD/SF, CF, CF/SF, CF-II/SF, SF/CC, SJ/CF, IS:13656-2002, EPL-1/EDL-1, VW500.00, 501.01, 505.00, ACEA A3-98, B3-98, BMW Special Oil និង MB 229.1។

- ផ្តល់ថាមពលខ្លាំងបំផុត និង ជួយសន្សំសំចៃប្រេងឥន្ធនៈ
- អាចប្រើប្រាស់បានយូរមុនពេលត្រូវប្តូរប្រេងម៉ាស៊ីនថ្មី
- ជួយពន្យារអាយុកាលប្រើប្រាស់របស់ម៉ាស៊ីន

Pure Gold

- ចំណាយលើការថែទាំទាបបំផុត
- កម្រិតនៃការប្រើប្រាស់ប្រេងម៉ាស៊ីនទាបបំផុត
- ងាយស្រួលក្នុងការបញ្ចេះម៉ាស៊ីន
- មានស្ថិរភាពខ្ពស់បំផុតចំពោះកម្តៅ
- ដំណើរការបានល្អក្នុងកម្រិតសីតុណ្ហភាពដ៏ទូលំទូលាយ

លក្ខណៈសម្បត្តិរូបវន្តទូទៅ

កម្រិតភាពខាប់ SAE	30	40	50
ដង់ស៊ីតេនៅសីតុណ្ហភាព 15°C kg/cu m	0.886	0.895	0.898
ភាពខាប់ Kinematic នៅសីតុណ្ហភាព 40°C (cSt)	100	151	220
ភាពខាប់ Kinematic នៅសីតុណ្ហភាព 100°C (cSt)	11.2	14.8	19.1
សន្ទស្សន៍ភាពខាប់ (Viscosity Index)	98	97	97
ចំណុចឆេះ (Flash Point, COC, °C)	226	236	242
ចំណុចកក (Pour Point, °C)	-18	-15	-9

ប្រេងម៉ាស៊ីនគុណភាពខ្ពស់ប្រភេទ Multigrade

កម្រិត (GRADE)

0W-30, 0W-40, 5W-30, 5W-40 (ប្រភេទសំយោគពេញលេញ ឬ Fully Synthetic)

សេចក្តីណែនាំ

ផលិតឡើងពីប្រេងមូលដ្ឋាន (Base stocks) ដែលបានចម្រាញ់យ៉ាងល្អិតល្អន់និងសារធាតុបន្ថែមដែលបានជ្រើសរើសយ៉ាងពិសេសដើម្បីបំពេញតាមលក្ខណៈពិសេសនិងកម្រិតសមត្ថភាពខ្ពស់ដូចជា៖ ស្ថិរភាពល្អប្រសើរចំពោះកម្តៅនិងការកត់ស៊ី (oxidation) ការការពារប្រឆាំងនឹងច្រែះ ការច្រេះ និងការសឹក។ ប្រេងនេះមានសន្ទស្សន៍ viscosity ខ្ពស់ ដែលជួយសម្រួលដល់ការបញ្ឆេះម៉ាស៊ីននៅពេលអាកាសធាតុត្រជាក់ និងធានាបាននូវកម្រាស់ស្រទាប់ប្រេងដ៏ល្អប្រសើរនៅពេលម៉ាស៊ីនមានសីតុណ្ហភាពខ្ពស់ខ្លាំង។ លក្ខណៈពិសេសទាំងនេះជួយលុបបំបាត់តម្រូវការក្នុងការផ្លាស់ប្តូរប្រេងតាមរដូវកាលកាត់បន្ថយការស៊ីប្រេង និងជួយរក្សាភាពស្អាតនៃម៉ាស៊ីន។

ការប្រើប្រាស់

ត្រូវបានណែនាំឱ្យប្រើសម្រាប់ម៉ាស៊ីនសាំងនិងម៉ាស៊ីនម៉ាស៊ូតដែលដំណើរការក្នុងកម្រិតសីតុណ្ហភាពខុសៗគ្នាជាច្រើនពេញមួយឆ្នាំ។

កម្រិតសមត្ថភាព និងអត្ថប្រយោជន៍

បំពេញតាមស្តង់ដារសមត្ថភាពដូចជា៖ API SN, SM, MIL-L-2014 B និង VW500.00, 501.01, 505.00, ACEA A3-98, B3-98, BMW Special Oil, MB 229.1 ។

- គ្រប់គ្រងការប្រើប្រាស់ប្រេងបានយ៉ាងល្អប្រសើរ
- ទប់ទល់នឹងការកត់ស៊ី (oxidation) ការកកើតកាកសំណល់ភក់ (sludge) នៅសីតុណ្ហភាពទាប និងការកកើតកំណកកំបោរឬកាកសំណល់នៅសីតុណ្ហភាពខ្ពស់បានយ៉ាងមានប្រសិទ្ធភាព
- កាត់បន្ថយការចំណាយលើការថែទាំ ដោយសារការបង្កើនអាយុកាលប្រើប្រាស់របស់ម៉ាស៊ីន
- មានស្ថិរភាពធន់នឹងកម្តៅកាន់តែប្រសើរឡើង
- មានលក្ខណៈសម្បត្តិល្អឥតខ្ចោះក្នុងការកាត់បន្ថយការកកិត និងជួយសម្អាតម៉ាស៊ីន

Pure Gold

- មានប្រសិទ្ធភាពខ្ពស់ក្នុងការការពារការសឹក ការកើតច្រែះ និងការច្រេះស៊ី (corrosion)

លក្ខណៈរូបវន្តទូទៅ

កម្រិតភាពខាប់ SAE	0W-30	5W-30	0W-40	5W-40
ដង់ស៊ីតេនៅ 15°C kg/cu m	0.849	0.848	0.848	0.851
ភាពខាប់ Kinematic នៅ 40°C, cSt	65.45	66.4	87.6	76.3
ភាពខាប់ Kinematic នៅ 100°C, cSt	12.5	12.1	15.9	13.8
សន្ទស្សន៍ភាពខាប់ (Viscosity Index)	196	183	195	187
ចំណុចឆេះ (Flash Point), COC, °C	216	228	214	224
ចំណុចហូរ (Pour Point), °C	-42	-39	-42	-39
TBN, mg KOH/g	8.3	8.3	8.3	8.3

ប្រេងម៉ាស៊ីនគុណភាពខ្ពស់ប្រភេទ Multigrade

កម្រិត (GRADE)

10W-30, 10W-40, 15W-40, 20W-40, 20W-50 (Semi-Synthetic / ពាក់កណ្តាលសំយោគ)

សេចក្តីណែនាំ

ផលិតឡើងពីប្រេងមូលដ្ឋាន (Base stocks) ដែលបានចម្រាញ់យ៉ាងល្អិតល្អន់ និងសារធាតុបន្ថែម(additives) ដែលត្រូវបានជ្រើសរើសយ៉ាងពិសេស ដើម្បីបំពេញតាមលក្ខណៈពិសេស និងកម្រិតសមត្ថភាពខ្ពស់ ដូចជា៖ ស្ថិរភាពល្អប្រសើរចំពោះកម្តៅ និងការកត់ស៊ី (oxidation) ការការពារប្រឆាំងនឹងច្រែះ ការច្រេះ និងការសឹក។ ប្រេងនេះមានសន្ទស្សន៍ viscosity ខ្ពស់ ដែលជួយសម្រួលដល់ការបញ្ចេះម៉ាស៊ីននៅពេលអាកាសធាតុត្រជាក់

និងធានាបាននូវកម្រាស់ស្រទាប់ប្រេងដ៏ល្អប្រសើរនៅពេលសីតុណ្ហភាពឡើងខ្ពស់ខ្លាំង។

លក្ខណៈពិសេសទាំងនេះជួយលុបបំបាត់តម្រូវការក្នុងការផ្លាស់ប្តូរប្រេងតាមរដូវកាល កាត់បន្ថយការស៊ីប្រេង និងជួយរក្សាភាពស្អាតនៃម៉ាស៊ីន។

ការប្រើប្រាស់

ត្រូវបានណែនាំឱ្យប្រើប្រាស់សម្រាប់ម៉ាស៊ីនសាំងនិងម៉ាស៊ុនម៉ាស៊ូត ដែលដំណើរការក្នុងកម្រិតសីតុណ្ហភាពខុសៗគ្នាជាច្រើនពេញមួយឆ្នាំ។

កម្រិតសមត្ថភាព និងអត្ថប្រយោជន៍

បំពេញតាមស្តង់ដារសមត្ថភាពដូចជា៖ API SN, SM; VW 500.00, 501.01, 505.00; ACEA A3-98, B3-98; BMW Special Oil និង MB 229.1។

- ពន្យារពេលនៃការផ្លាស់ប្តូរប្រេងម៉ាស៊ីន
- ពន្យារអាយុកាលប្រើប្រាស់របស់ម៉ាស៊ីន
- កាត់បន្ថយការចំណាយលើការថែទាំ ដោយសារអាយុកាលម៉ាស៊ីនប្រើប្រាស់បានយូរជាងមុន
- កាត់បន្ថយការចំណាយលើប្រតិបត្តិការដោយសារប្រសិទ្ធភាពប្រេងម៉ាស៊ីននិងប្រេងឥន្ធនៈកាន់តែប្រសើរឡើង
- មានស្ថិរភាពកម្តៅខ្ពស់បំផុត
- មានលក្ខណៈសម្បត្តិល្អប្រសើរក្នុងការកាត់បន្ថយការកកិត និងសម្អាតម៉ាស៊ីន

លក្ខណៈសម្បត្តិរូបវន្តទូទៅ

កម្រិត (Viscosity) SAE	10W-30	10W-40	15W-40	20W-50
ដង់ស៊ីតេ @ 15°C kg/cu m	0.871	0.874	0.885	0.892

Pure Gold

Kinematic Viscosity @ 40°C , cSt	74	91	98.8	142
Kinematic Viscosity @ 100°C , cSt	12.2	14.2	14.84	18.5
សន្ទស្សន៍ (Viscosity Index)	164	162	157	147
ចំណុចឆេះ (Flash Point), COC, °C	220	220	224	236
ចំណុចត្រជាក់ (Pour Point), °C	-33	-33	-27	-24
TBN, mg KOH/g	8.3	8.3	8.3	8.3

ប្រេងម៉ាស៊ីនប្រភេទ Super Multigrade

កម្រិត (Grade)

15W-40, 20W-40, 20W-50

សេចក្តីណែនាំ

ផលិតឡើងពីប្រេងមូលដ្ឋាន (Base stocks) ដែលបានចម្រាញ់យ៉ាងល្អិតល្អន់ និងសារធាតុបន្ថែមដែលបានជ្រើសរើសយ៉ាងពិសេសដើម្បីបំពេញតាមលក្ខណៈពិសេសនិងកម្រិតសមត្ថភាពខ្ពស់ដូចជា៖ស្ថិរភាពល្អប្រសើរចំពោះកម្តៅនិងការកត់ស៊ី (oxidation)ការការពារប្រឆាំងនឹងច្រែះ ការច្រេះ និងការសឹក។ប្រេងនេះមានសន្ទស្សន៍ viscosity (កម្រិតភាពខាប់)ខ្ពស់ដែលជួយសម្រួលដល់ការបញ្ឆេះម៉ាស៊ីននៅពេលអាកាសធាតុត្រជាក់ និងធានាបាននូវកម្រិតកម្រាស់ស្រទាប់ប្រេងគ្រប់គ្រាន់នៅពេលសីតុណ្ហភាពឡើងខ្ពស់ខ្លាំង។ លក្ខណៈពិសេសទាំងនេះជួយលុបបំបាត់តម្រូវការក្នុងការផ្លាស់ប្តូរប្រេងតាមរដូវកាលកាត់បន្ថយការប្រើប្រាស់ប្រេង និងជួយរក្សាភាពស្អាតនៃម៉ាស៊ីន។

ការប្រើប្រាស់

ត្រូវបានណែនាំឱ្យប្រើប្រាស់សម្រាប់ម៉ាស៊ីនសាំងនិងម៉ាស៊ីនម៉ាស៊ូតដែលដំណើរការក្នុងកម្រិតសីតុណ្ហភាពខុសៗគ្នាជាច្រើនពេញមួយឆ្នាំ។

កម្រិតសមត្ថភាព និង អត្ថប្រយោជន៍

បំពេញតាមកម្រិតសមត្ថភាពដូចជា៖ API CC/SC, SL/CF, SJ/CF, SG/CD, SF/CC, CJ4/SM, CI-4/SL, CH-4/SJ, CG-4/SH, CF-4/SJ, CF/SF, CF-II/SF, MIL-L-2014 B, IS:13656-2002, E-PL1/E-DL1, VW500.00, 501.01, 505.00, ACEA A3-98, B398, BMW Special Oil, MB 229.1។

- គ្រប់គ្រងការប្រើប្រាស់ប្រេងបានយ៉ាងល្អប្រសើរ
- សន្សំសំចៃប្រេងឥន្ធនៈបានល្អ និងងាយស្រួលបញ្ឆេះម៉ាស៊ីននៅពេលត្រជាក់
- អាចប្រើប្រាស់បានយ៉ាងល្អឥតខ្ចោះជាមួយប្រព័ន្ធ Catalyst និង Turbo/Multivalve
- មានស្ថិរភាពធន់នឹងកម្តៅខ្ពស់
- មានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយការកកិត និងសម្អាតម៉ាស៊ីន
- ការពារការសឹក ការកើតប្រេះ និងការច្រេះស៊ី (corrosion) បានយ៉ាងមានប្រសិទ្ធភាព

លក្ខណៈសម្បត្តិរូបវន្តទូទៅ

កម្រិតភាពខាប់ SAE	15W-40	20W-50
ដង់ស៊ីតេនៅសីតុណ្ហភាព 15°C kg/cu m	0.885	0.892
ភាពខាប់ Kinematic នៅ 40°C (cSt)	98.8	142
ភាពខាប់ Kinematic នៅ 100°C (cSt)	14.84	18.5
សន្ទស្សន៍ភាពខាប់ (Viscosity Index)	157	147

ចំណុចបញ្ឆេះ/Flash Point (COC, °C)	224	236
ចំណុចចាប់ផ្តើមហូរ/Pour Point (°C)	-27	-24
TBN (mg KOH/g)	6.5 – 9.3	6.5 – 9.3

ប្រេងម៉ាស៊ីនសម្រាប់ម៉ាស៊ីន ២ វគ្គ (2-Stroke)

ប្រភេទ (Grade)

ប្រេងម៉ាស៊ីន ២ វគ្គ

សេចក្តីផ្តើម

ប្រេង 2T គឺជាប្រេងម៉ាស៊ីន ២ វគ្គប្រភេទពាក់កណ្តាលសំយោគ (semi-synthetic) ដែលមានផ្សែងតិចហើយត្រូវបានបង្កើតឡើងដើម្បីបំពេញតាមតម្រូវការដ៏សំខាន់របស់ម៉ាស៊ីន ២ វគ្គ ដែលផលិតដោយក្រុមហ៊ុនផលិតយានយន្តឈានមុខគេទាំងអស់។ វាត្រូវបានលាយបញ្ចូលគ្នាពីប្រេងមូលដ្ឋាន(Base stocks) ដែលបានជ្រើសរើសយ៉ាងយកចិត្តទុកដាក់និងសារធាតុបន្ថែមពិសេស ដើម្បីកាត់បន្ថយការកកើតកាកសំណល់នៅលើ ក្បាលទៀន(spark plug)និងការឆេះមុនកំណត់ (pre-ignition) ការពារការច្រេះ កាត់បន្ថយការកកើតកាកសំណល់ក្នុងម៉ាស៊ីន និងផ្តល់ការការពារប្រឆាំងនឹងការជាប់គាំង (seizure)ការកកិតខ្លាំង (scuffing) និងការសឹក។ វាត្រូវបានបង្កើតឡើងជាពិសេសដើម្បីជួយកាត់បន្ថយការប្រើប្រាស់ប្រេងឥន្ធនៈ។ វាមានផ្ទុកសារធាតុរំលាយ (diluents) ដើម្បីងាយស្រួលលាយជាមួយសាំង និងមានពណ៌បៃតងដើម្បីងាយស្រួលសម្គាល់។

ការប្រើប្រាស់

ប្រេង 2T ត្រូវបានណែនាំសម្រាប់ប្រើប្រាស់ជាប្រេងរំអិលសម្រាប់ម៉ូតូស្កូតឺ (scooters) រ៉ឺម៉កម៉ូតូ (auto rickshaws) ម៉ូតូធម្មតា និងម៉ូតូដែលមានម៉ាស៊ីន ២ វគ្គ។ កម្រិតប្រើប្រាស់ដែលបានណែនាំគឺ ប្រេង 20 មីលីលីត្រ (ml) ក្នុងមួយលីត្រសាំង។

កម្រិតសមត្ថភាព និងអត្ថប្រយោជន៍

ប្រេង 2T ឆ្លើយតបទៅនឹងកម្រិតសមត្ថភាពនៃស្តង់ដារ JASO FC, API TC, CEC TSC-3 និង TISI។

- បញ្ចេញផ្សែងតិច
- រក្សាភាពស្អាតរបស់ម៉ាស៊ីន
- កាត់បន្ថយការកកើតកាកសំណល់លើក្បាលទៀន
- កាត់បន្ថយការកកើតកាកសំណល់នៅច្រកចេញចូល (port deposits) និងការជាប់គាំងនៃចិញ្ចៀនស្តុង (ring sticking)
- ការពារការជាប់គាំង និងការកកិតខ្លាំងរបស់ម៉ាស៊ីន
- ងាយស្រួលបូមដោយប្រព័ន្ធចាក់ប្រេង (oil injection system)
- ធានាការកាត់បន្ថយការប្រើប្រាស់ប្រេង

លក្ខណៈរូបវន្តទូទៅ

កម្រិត(Viscosity) SAE	30
ដង់ស៊ីតេ @ 15°C kg/cu m	0.860
Kinematic @ 40°C, cSt	70
Kinematic @ 100°C, cSt	9.5
សន្ទស្សន៍ (Viscosity Index)	115

ចំណុចឆេះ (Flash Point), COC, °C	200
ចំណុចកក (Pour Point), °C	-21
TBN, mg KOH/g	2.5
ផេះស៊ុលហ្វាត (Sulphates Ash), % ដោយទម្ងន់, អតិបរមា	0.25

ប្រេងម៉ាស៊ីនសម្រាប់ម៉ាស៊ីន ៤ ហ្សង់4 Stroke)

កម្រិតគុណភាព (Grade)

4T 20W-40, 4T 20W-50

សេចក្តីណែនាំ

នេះគឺជាប្រេងម៉ាស៊ីន ៤ ហ្សង់ (4-stroke) ប្រភេទ multigrade ដែលមានប្រសិទ្ធភាពខ្ពស់។ វាត្រូវបានផលិតឡើងពីប្រេងមូលដ្ឋាន (Base stocks) ដែលបានចម្រាញ់យ៉ាងល្អិតល្អន់ និងសារធាតុបន្ថែមពិសេសដើម្បីធន់នឹងសីតុណ្ហភាពខ្ពស់ក្នុងពេលម៉ាស៊ីនដំណើរការ សម្រាប់ប្រើប្រាស់ជាមួយម៉ូតូ ឬយានយន្តពីរបីកង់ដែលមានម៉ាស៊ីន ៤ ហ្សង់ និងប្រព័ន្ធត្រជាក់ដោយខ្យល់ (air-cooled)។ ប្រេងនេះមានស្ថិរភាពល្អប្រសើរក្នុងការទប់ទល់នឹងការកត់ស៊ី (oxidation) និងជួយកាត់បន្ថយការកកើតនៃកាកសំណល់ (sludge) និងស្រទាប់កខ្វក់ (varnish) នៅក្នុងម៉ាស៊ីន។ លើសពីនេះ វាជួយការពារការសឹករបស់ម៉ាស៊ីន ពន្យារអាយុកាលម៉ាស៊ីន បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ប្រេងឥន្ធនៈ និង រក្សាភាពស្អាតល្អឥតខ្ចោះដល់ម៉ាស៊ីន។

ការប្រើប្រាស់

ត្រូវបានណែនាំឱ្យប្រើជាប្រេងម៉ាស៊ូតសម្រាប់គោលបំណងចម្រុះ ដើម្បីផ្តល់ការរំអិលដល់ម៉ាស៊ូត ៤ ហ្សង់ សម្រាប់យានយន្តពីរ-បីកង់គ្រប់ម៉ូដែល រួមមានម៉ូតូ ម៉ូតូស្កូតឺ (scooters) និងរ៉ឺម៉កម៉ូតូ (auto rickshaws) ដែលប្រើប្រាស់ប្រេងសាំង និងឧស្ម័ន CNG/LPG។

កម្រិតប្រសិទ្ធភាព និងអត្ថប្រយោជន៍

បំពេញតាមស្តង់ដារប្រសិទ្ធភាព៖ API SL/CF, JASO T 903 (ស្តង់ដារ MA2), Cummins, MWM Deutz*, Rolls Royce(Ulstein Bergen),MTU*MAN,Wartsila*,Perkins*,Caterpillar,Waukesha (កម្រិតផេះអប្បបរមា0.35%)*។

- ភាពធន់ខ្ពស់ចំពោះការកត់ស៊ី (oxidation) និងការបង្កើតនីត្រាត (nitration) ជួយការពារការច្រេះនៃទ្រនាប់ (bearing)

- ភាពស្អាតនៃម៉ាស៊ូតជួយកាត់បន្ថយការសឹករបស់ម៉ាស៊ូត ពន្យារអាយុកាលប្រើប្រាស់របស់គ្រឿងបន្លាស់ រក្សាសមត្ថភាពថាមពលម៉ាស៊ូត បង្កើនស្ថិរភាពប្រតិបត្តិការ និងកាត់បន្ថយចំណាយលើការថែទាំ

- កម្រិតផេះស៊ុលហ្វាត (sulfated ash) ដែលមានតុល្យភាព ជួយពន្យារអាយុកាលប្រើប្រាស់របស់វ៉ាល់ និងក្បាលទៀន (spark plugs)

-កម្រិតផ្ទុស្វ័រទាបធានាបាននូវភាពឆបគ្នាជាមួយម៉ាស៊ូតដែលបំពាក់ដោយប្រព័ន្ធកាតាលីករកាត់បន្ថយការបំភាយឧស្ម័នពុល (emission catalysts)

លក្ខណៈរូបវន្តទូទៅ

កម្រិតភាពខាប់ SAE	20W-40	20W-50
ដង់ស៊ីតេនៅសីតុណ្ហភាព 15°C kg/cu m	0.885	0.892
ភាពខាប់Kinematicនៅសីតុណ្ហភាព 40°C (cSt)	98.8	142

ភាពខាប់ Kinematic នៅសីតុណ្ហភាព 100°C (cSt)	14.84	18.5
សន្ទស្សន៍ភាពខាប់ (Viscosity Index)	157	147
ចំណុចឆេះ (Flash Point, COC, °C)	224	224
ចំណុចកក (Pour Point, °C)	-24	-24
TBN (mg KOH/g)	8.3	8.3

ប្រេងម៉ាស៊ីនម៉ាស៊ូតសម្រាប់រថភ្លើង (Railroad Diesel Oil)

កម្រិតគុណភាព (GRADE)

SAE 40

សេចក្តីណែនាំ

ជាប្រេងរំអិលគុណភាពខ្ពស់សម្រាប់ម៉ាស៊ីនធុនធ្ងន់ដែលគ្មានសារធាតុស័ង្កសី (zinc-free)។ វាត្រូវបានផលិតឡើងដោយប្រើប្រេងមូលដ្ឋាន (Base Oil) ដែលបានចម្រាញ់យ៉ាងល្អ និងសារធាតុបន្ថែមពិសេសសម្រាប់ម៉ាស៊ីនម៉ាស៊ូតដែលមានល្បឿនមធ្យម ដែលប្រើប្រាស់ក្នុងវិស័យផ្លូវដែក និងតម្រូវឱ្យមានប្រេងរំអិលតាមស្តង់ដារ LMOA Generation 5។

ការប្រើប្រាស់

ត្រូវបានណែនាំសម្រាប់ម៉ាស៊ីនម៉ាស៊ូតជំនាន់ថ្មីរបស់ GM-EMD និង General Electric ដែលបំពាក់ដោយទ្រនាប់ប្រាក់ (silver bearing) នៅក្នុងក្បាលរថភ្លើង ក៏ដូចជាម៉ាស៊ីនស្តានី និងម៉ាស៊ីនលើនាវាដែលប្រើប្រាស់ឥន្ធនៈមានកម្រិតស្ពាន់ធ័រខ្ពស់។ វាក៏អាចប្រើសម្រាប់វិស័យឧស្សាហកម្មដែលតម្រូវឱ្យប្រើប្រាស់ប្រេងគ្មានសារធាតុស័ង្កសីដូចជានៅលើរទិកាខួងយកប្រេងនៅសមុទ្រ ទូកអូស (tugs) និងទូកនេសាទ។

កម្រិតសមត្ថភាព និងអត្ថប្រយោជន៍

API CD, US MIL-L-2014, ម៉ាស៊ីន General Electric និង General Motor-Electro Motive Division (GM-EMD), General 5, DALIAN Locomotive ។

- មានភាពធន់នឹងកម្តៅខ្ពស់ និងស្ថិរភាពប្រឆាំងនឹងការកត់ស៊ី (oxidation) បានយ៉ាងល្អប្រសើរ

-ការពារយ៉ាងល្អឥតខ្ចោះប្រឆាំងនឹងការសឹក ការជាប់ចិញ្ចៀនស្តុង (ring sticking) ការកើតច្រែះ និងការច្រេះស៊ី ដើម្បីធានាអាយុកាលប្រើប្រាស់បានយូរនៃផ្នែកដែលធ្វើចលនា និងកាត់បន្ថយតម្រូវការក្នុងការថែទាំម៉ាស៊ីន

-មានគុណភាពសម្អាត និងបំបែកកាកសំណល់ (detergent and dispersant) ដ៏ល្អឥតខ្ចោះ ដើម្បីរក្សាភាពស្អាតរបស់ម៉ាស៊ីន

-រក្សាកម្រិត TBN បានយ៉ាងមានប្រសិទ្ធភាពខ្ពស់

លក្ខណៈរូបវន្តទូទៅ

កម្រិត (Viscosity) SAE	40
ដង់ស៊ីតេ (Density) នៅ15°C kg/cu m	0.895
Kinematic នៅ 40°C, cSt	151
Kinematic នៅ 100°C, cSt	14.8
សន្ទស្សន៍ (Viscosity Index)	97
ចំណុចឆេះ (Flash Point), COC, °C	236
ចំណុចកក (Pour Point), °C	-9
TBN, mg KOH/g	20

ផេះស៊ុលហ្វាត (Sulfated Ash), % wt	2.3

ប្រព័ន្ធបញ្ជូនកម្លាំង (Drive Line)

កម្រិត (GRADE)

ប្រេងលេខ (Gear Oil) ប្រភេទ EP 90, EP 140, 80W-90, 85W-140

សេចក្តីណែនាំ

គឺជាប្រេងរំអិលសម្រាប់ប្រអប់លេខយានយន្តដែលត្រូវបានផលិតឡើងដើម្បីទ្រទ្រង់សម្ពាធខ្ពស់ (Extreme Pressure)។ ប្រេងទាំងនេះត្រូវបានលាយបញ្ចូលគ្នារវាងប្រេងមូលដ្ឋាន (Base Oil) ដែលបានជ្រើសរើស យ៉ាងពិសេសនិងសារធាតុបន្ថែម ដើម្បីផ្តល់នូវលក្ខណៈសម្បត្តិក្នុងការទ្រទ្រង់សម្ពាធខ្ពស់ និងការពារការច្រេះ។

ការប្រើប្រាស់

ត្រូវបានណែនាំសម្រាប់រថយន្តដឹកអ្នកដំណើរ រថយន្តក្រុង និងរថយន្តដឹកទំនិញធុនធ្ងន់ ដើម្បីរំអិលប្រព័ន្ធអ័ក្សដែលមានប្រអប់លេខប្រភេទHypoid,Spiral BevelនិងWorm Gearព្រមទាំងប្រអប់លេខដៃ(manual transmission)ដែលតម្រូវឱ្យប្រើប្រាស់ប្រេងរំអិលប្រភេទ EP នេះ។

កម្រិតសមត្ថភាព និងអត្ថប្រយោជន៍

បំពេញតាមកម្រិតសមត្ថភាពនៃស្តង់ដារAPI ប្រភេទGL-1, GL-4, GL-5, IS:1118-1992 EP Type GL-4; ស្តង់ដារយោធាអាមេរិក MIL-L-2105D; MB 235.0; MAN 342 Type M-1; DAF; Voith 3.325-339; Volvo 97310/97316; និង Renault។

-មានសមត្ថភាពខ្ពស់ក្នុងការបំបែកទឹកចេញពីប្រេង(demulsibility)ព្រមទាំងមានស្ថិរភាពល្អចំពោះកម្តៅនិងការកត់ស៊ី

-ផ្តល់ការការពារដ៏ល្អប្រសើរប្រឆាំងនឹងការបង្កើតពពុះខ្យល់ ការកើតច្រេះ និងការច្រេះស៊ុលហ:

-អាចប្រើប្រាស់បានយ៉ាងល្អជាមួយគ្រឿងបន្ថាស់ប្រភេទស៊ីល (seals) គ្រប់ប្រភេទ ដើម្បីការពារការលេចធ្លាយ

-មានភាពធន់ខ្ពស់ប្រឆាំងនឹងការខូចខាតធ្មេញហ្គែរ (gear distress) ក្នុងលក្ខខណ្ឌប្រតិបត្តិការផ្សេងៗដូចជា៖ ល្បឿនលឿនជាមួយកម្លាំងប៉ះទង្គិច(shock-load) ល្បឿនលឿនជាមួយកម្លាំងបង្វិលទាប និងល្បឿនយឺតជាមួយកម្លាំងបង្វិលខ្ពស់

-មានកម្រិតសមត្ថភាពសម្អាត (detergency) ត្រឹមត្រូវ ដើម្បីធានាថាប្រព័ន្ធដំណើរការមានភាពស្អាតល្អ

-មិនបង្កការច្រេះស៊ីដល់ដែក ទង់ដែង ឬលោហៈ និងលោហៈលាយផ្សេងទៀតឡើយ ហើយជួយរក្សាគ្រឿងបន្ថាស់ឱ្យនៅមានគុណភាពល្អបំផុត

លក្ខណៈរូបវន្តទូទៅ

កម្រិត viscosityតាមស្តង់ដារSAE	80W-90	85W-140	90	140
ដង់ស៊ីតេនៅសីតុណ្ហភាព 15°C kg/cu m	0.886	0.907	0.889	0.910
Kinematic Viscosity នៅសីតុណ្ហភាព 40°C (cSt)	159	360	220	460
Kinematic Viscosityនៅសីតុណ្ហភាព100°C (cSt)	15.5	26	19.2	31
សន្ទស្សន៍ Viscosity (Viscosity Index)	99	95	97	95
ចំណុចបញ្ឆេះ (Flash Point, COC, °C)	176	220	182	226
ចំណុចចាប់ផ្តើមហូរ (Pour Point, °C)	-27	-12	-12	-6

សារធាតុត្រជាក់ (Coolants)

ផលិតផល៖ សារធាតុត្រជាក់សម្រាប់រ៉ាឌីយ៉ាទ័រ (Radiator Coolant)

Pure Gold

កម្រិត៖ ប្រភេទខាប់ (Concentrated)

សេចក្តីណែនាំ

វាគឺជាសារធាតុត្រជាក់សំយោគសម្រាប់រ៉ាឌីយ៉ាទ័រដែលមានគុណភាពខ្ពស់ ដែលគ្មានសារធាតុ amines, borates, silicates និង phosphates។ វាអាចលាយជាមួយទឹកបានយ៉ាងងាយស្រួលនិងមានស្ថិរភាពល្អប្រសើរនៅពេលប្រើជាមួយទឹកដែលមានជាតិរ៉ែខ្ពស់ (hard water)។ វាមានស្ថិរភាពគីមីល្អ ព្រមទាំងមានចំណុចពុះខ្ពស់ និងចំណុចត្រជាក់កកទាបដែលសាកសមសម្រាប់ការប្រើប្រាស់ទាំងក្នុងរដូវក្តៅ និងរដូវរងា។

ការប្រើប្រាស់

ត្រូវបានណែនាំឱ្យប្រើសម្រាប់ម៉ាស៊ីនយានយន្ត (ទាំងប្រភេទចល័ត និងស្ថានី) ដែលមានប្រព័ន្ធចរន្តសារធាតុត្រជាក់បែបបិទជិត (closed-loop system)។ គួរលាយសារធាតុខាប់នេះក្នុងសមាមាត្រ 1 ផ្នែក ជាមួយទឹក 2 ផ្នែក (និយមប្រើទឹកដែលបានដកជាតិរ៉ែចេញ ឬ Demineralised Water) សម្រាប់ចាក់ចូលក្នុងរ៉ាឌីយ៉ាទ័រម៉ាស៊ីនឬអនុវត្ត តាមការណែនាំរបស់អ្នកផលិតដើម(OEM)។

កម្រិតសមត្ថភាព និងអត្ថប្រយោជន៍

វាបំពេញតាមតម្រូវការនៃ៖

- JIS K-2234-1934, ASTM D 3306, JAGUAR APPROVAL, OPEL-VANXHALL QL 1301000
- IS: 5759-1994, MAN 324, BMW N 600 69, FORD ESD-M97B-49A, VOLKSWAGEN TL 774B/C

-ផ្តល់ការការពារប្រកបដោយប្រសិទ្ធភាព និងយូរអង្វែងប្រឆាំងនឹងការច្រេះសម្រាប់គ្រប់ផ្នែកលោហៈនៃម៉ាស៊ីន និងប្រព័ន្ធត្រជាក់

-អាចប្រើប្រាស់បានជាមួយទុយយោជ័រកៅស៊ូ និងគ្រឿងបន្ទាស់ការពារការលេចធ្លាយ (seals)

-មានចំណុចត្រជាក់កកទាប ដែលជួយការពារការប្រេះបែកតួម៉ាស៊ីន(engine block) នៅពេលសីតុណ្ហភាពចុះទាបបំផុត

-ការពារការហួតខ្លាំងពេក និងការហៀរចេញដោយសារពុះខ្លាំង

លក្ខណៈរូបវន្តទូទៅ

កំហាប់Concentration	100%
ពណ៌Color	ខៀវBlue
ដង់ស៊ីតេនៅសីតុណ្ហភាព 15°C kg/cu m	1.128
កម្រិតភាពស្អិត (Kinematic Viscosity) នៅ20°C (cSt)	23
ចំណុចឆេះ (Flash Point - PMCC) (°C)	118
បរិមាណទឹក (% ដោយទម្ងន់)	2.4
បរិមាណស៊ីលីកាត (% ដោយទម្ងន់)	0.11
ចំណុចត្រជាក់កក (លាយ 50% v/v ជាមួយទឹកចម្រោះ) (°C)	-39
ចំណុចត្រជាក់កក (លាយ 33% v/v ជាមួយទឹកចម្រោះ) (°C)	-20
តម្លៃ pH (លាយ 50% v/v ជាមួយទឹកចម្រោះ)	7.7

ATF Dextron II & III

ផលិតផល៖

ប្រេងសម្រាប់ប្រព័ន្ធបញ្ជូនកម្លាំងស្វ័យប្រវត្តិ (Automatic Transmission Fluid)

Pure Gold

កម្រិតគុណភាព (Grade)

ប្រភេទ Dextron II និង III របស់ក្រុមហ៊ុន General Motors សហរដ្ឋអាមេរិក

សេចក្តីណែនាំ

វាគឺជាប្រេងប្រព័ន្ធបញ្ជូនកម្លាំងដែលមានគុណភាពខ្ពស់ មានពណ៌ក្រហម និងមានកម្រិតកកិតទាប ដើម្បី ឆ្លើយតបទៅនឹងស្តង់ដារបច្ចេកទេស។ ប្រេងនេះត្រូវបានផ្សំឡើងដោយសារធាតុបន្ថែម (additives) ដែលបាន ជ្រើសរើសយ៉ាងយកចិត្តទុកដាក់ ដើម្បីផ្តល់នូវលក្ខណៈសម្បត្តិដូចជា៖ ធន់នឹងការកត់ស៊ីដោយសារកម្តៅ បានល្អ, អាចហូរបានល្អនៅសីតុណ្ហភាពទាបខ្លាំង, ប្រើប្រាស់បានល្អជាមួយគ្រឿងបន្លាស់ប្រភេទស៊ីល(seal) ដោយមិនបង្កការខូចខាត, ព្រមទាំងមានសមត្ថភាពការពារការសឹក និងការពារការច្រេះ។ ប្រេងដែលមាន សន្ទស្សន៍ viscosity ខ្ពស់នេះ ធានាបាននូវការប្តូរលេខដោយរលូន និងកាត់បន្ថយការបាត់បង់ថាមពលដល់ កម្រិតអប្បបរមា។

ការប្រើប្រាស់

ត្រូវបានណែនាំឱ្យប្រើប្រាស់សម្រាប់ទាំងរថយន្តដឹកអ្នកដំណើរ និងរថយន្តដឹកទំនិញធុនស្រាល ដែលត្រូវការប្រេងសម្រាប់ប្រព័ន្ធបញ្ជូនកម្លាំងស្វ័យប្រវត្តិ (automatic transmission) ប្រព័ន្ធចង្កូតជំនួយដោយថាមពល (power steering) និងប្រព័ន្ធហ្គែរប្រភេទ synchromesh។

កម្រិតសមត្ថភាព និងអត្ថប្រយោជន៍

បំពេញតាមកម្រិតសមត្ថភាព DEXTRON II និង III របស់ក្រុមហ៊ុន General Motors (GM) សហរដ្ឋអាមេរិក៖

Dexron III (H)/IIE, ZF TE-ML 03D-09B-14D, Ford MERCON, Caterpillar TO-2,Allison C-4, Mercedes Benz Sheet 236.9, Voith G 607

-ដំណើរការល្អប្រសើរក្នុងអាកាសធាតុត្រជាក់

-ធន់នឹងការបង្កើតពពុះខ្យល់ (foaming) ការកើតច្រែះ និងការច្រេះស៊ី (corrosion) បានយ៉ាងល្អពិសេស

-រក្សាភាពស្អាត និងស្ថិរភាពបានល្អប្រសើរនៅសីតុណ្ហភាពខ្ពស់

-មានស្ថិរភាពប្រឆាំងនឹងការកត់ស៊ី (oxidation) បានប្រសើរជាងមុន

-រក្សាលក្ខណៈសម្បត្តិនៃកម្លាំងកកិត (friction) បានល្អប្រសើរដើម្បីធានាឱ្យប្រព័ន្ធ Clutch និងហ្វ្រាំងដំណើរការបានរលូន និងគ្មានបញ្ហា

លក្ខណៈរូបវន្តទូទៅ

ពណ៌ Color	ATF-II	ATF-III
ដង់ស៊ីតេនៅសីតុណ្ហភាព 15°C kg/cu m	0.865	0.860
កម្រិត viscosity (Kinematic) នៅ40°C , cSt	33.8	33.8
កម្រិតviscosity (Kinematic) នៅ100°C , cSt	7.3	7.3
សន្ទស្សន៍Viscosity Index	175	175
ចំណុចឆេះFlash Point (COC), °C	180	180
ចំណុចកក Pour Point , °C	-45	-45
ការធ្វើតេស្តកម្លាំងកកិត Clutch Friction Test	Pass	Pass
ការធ្វើតេស្តដំណើរការវិលជុំ Cycling Test	Pass	Pass
Brookfield viscosity (cP) @ -40°C	36000	18700

Pure Gold

ប្រេងហ្វ្រាំង DOT-3

កម្រិតគុណភាព (GRADE)

DOT-3

សេចក្តីណែនាំ

វាគឺជាប្រេងហ្វ្រាំងប្រភេទសំយោគពេញលេញ (fully synthetic) ដែលមានគុណភាពខ្ពស់ និងប្រសិទ្ធភាពខ្ពស់ សម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធហ្វ្រាំងធារាសាស្ត្រដែលទទួលរងបន្ទុកធ្ងន់។ វាមានផ្ទុកសារធាតុប្រឆាំងអុកស៊ីតកម្ម សារធាតុទប់ស្កាត់ប្រតិកម្មលោហៈ និងសារធាតុការពារការច្រេះ ដើម្បីធានាបាននូវអាយុកាលប្រើប្រាស់បានយូរ ទាំងសម្រាប់ប្រេងហ្វ្រាំង និងគ្រឿងបន្លាស់ប្រព័ន្ធហ្វ្រាំង។ ដោយសារវាមានចំណុចពុះខ្ពស់(Equilibrium Reflux Boiling Point ឬ ERBP លើសពី ២០៥អង្សាសេ) បញ្ហាស្ទះចំហាយ(vapor locking)ត្រូវបានកាត់បន្ថយយ៉ាងខ្លាំង នៅពេលដំណើរការក្នុងសីតុណ្ហភាពខ្ពស់ ជាពិសេសនៅក្នុងទីក្រុងដែលមានស្ថានភាពចរាចរណ៍ត្រូវឈប់និងចេញដំណើរញឹកញាប់ ដែលតម្រូវឱ្យមានការប្រើប្រាស់ហ្វ្រាំងជាប្រចាំ។ លក្ខណៈពិសេសដ៏ល្អប្រសើររបស់វាក្នុងសីតុណ្ហភាពទាប អនុញ្ញាតឱ្យវាដំណើរការបានល្អរហូតដល់សីតុណ្ហភាព -៤០អង្សាសេ។

ការប្រើប្រាស់

ត្រូវបានណែនាំសម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធហ្វ្រាំងធារាសាស្ត្រសម័យទំនើប រួមទាំងប្រភេទហ្វ្រាំងឌីស(disc) និងហ្វ្រាំងស្គរ (drum)។

កម្រិតប្រសិទ្ធភាព និងអត្ថប្រយោជន៍

FMVSS 116 DOT-3, SAE J 1703, IS:8654-2001
-លក្ខណៈហូរបានល្អប្រសើរ ធានាបាននូវដំណើរការប្រកបដោយប្រសិទ្ធភាពនៅសីតុណ្ហភាពទាបខ្លាំង

-កម្រិតភាពខាប់(viscosity)សមស្របទាំងនៅសីតុណ្ហភាពធម្មតា និងសីតុណ្ហភាពខ្ពស់

-បង្កើនភាពធន់នឹងអុកស៊ីតកម្ម និងស្ថិរភាពកម្តៅ

-សមត្ថភាពរំអិលដ៏ល្អឥតខ្ចោះ ដើម្បីកាត់បន្ថយការកកិត និងការសឹក(wear)រវាងពីស្តុង និងស៊ីឡាំងនៅក្នុងប្រព័ន្ធហ្វ្រាំង

-ប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំណើម ធានាបាននូវសុវត្ថិភាពប្រព័ន្ធហ្វ្រាំងក្នុងរយៈពេលវែង

-អាចប្រើប្រាស់បានយ៉ាងល្អឥតខ្ចោះជាមួយគ្រឿងបន្លាស់ប្រភេទអេឡាស្តូម៉ែរ (elastomers) ដើម្បីការពារបញ្ហាជាមួយហ្គាសស្គីត (gaskets) និងស៊ីល (seals)

-ការពារការកើតច្រែះ និងការច្រេះបានយូរអង្វែង

លក្ខណៈរូបវន្តទូទៅ

កម្រិតFMVSS	DOT 3
ដង់ស៊ីតេនៅ ១៥អង្សាសេ, kg/cu m	1.004
ភាពខាប់ Kinematic នៅ 40°C , cSt	1400
ភាពខាប់ Kinematic នៅ100°C , cSt	2.2
ចំណុចពុះEquilibrium Reflex Boiling Point (ERBP), ^{0}C	225
ចំណុចពុះWet ERBP, ^{0}C	149
តម្លៃ pH	8.7

ប្រេងហ្វ្រាំង DOT-4

Pure Gold

កម្រិតគុណភាព (GRADE)

DOT-4

សេចក្តីណែនាំ

វាគឺជាប្រេងហ្វ្រាំងប្រភេទសំយោគពេញលេញ (fully synthetic) ដែលមានគុណភាពខ្ពស់ និងដំណើរការល្អ ប្រសើរសម្រាប់ប្រព័ន្ធហ្វ្រាំងធារាសាស្ត្រដែលទទួលរងបន្ទុកធ្ងន់។ វាមានផ្ទុកសារធាតុប្រឆាំងអុកស៊ីតកម្ម សារធាតុទប់ស្កាត់ប្រតិកម្មលោហៈនិងសារធាតុការពារការច្រេះដើម្បីធានាអាយុកាលប្រើប្រាស់បានយូរទាំងសម្រាប់ប្រេងហ្វ្រាំង និងគ្រឿងបន្លាស់ប្រព័ន្ធហ្វ្រាំង។ ដោយសារវាមានចំណុចពុះខ្ពស់(លើសពី 240°C) បញ្ហាកើតមានចំហាយក្នុងប្រព័ន្ធហ្វ្រាំង (vapor lock) ត្រូវបានកាត់បន្ថយយ៉ាងខ្លាំងនៅពេលដំណើរការក្នុងសីតុណ្ហភាពខ្ពស់ ជាពិសេសនៅក្នុងទីក្រុងដែលមានស្ថានភាពចរាចរណ៍ត្រូវឈប់ និងចេញដំណើរញឹកញាប់ដែលតម្រូវឱ្យមានការប្រើប្រាស់ហ្វ្រាំងជាប្រចាំ។ លក្ខណៈពិសេសរបស់វាក្នុងការរក្សាភាពរាវនៅសីតុណ្ហភាពទាប អនុញ្ញាតឱ្យវាដំណើរការបានល្អរហូតដល់សីតុណ្ហភាព -40°C។

ការប្រើប្រាស់

ត្រូវបានណែនាំសម្រាប់ប្រព័ន្ធហ្វ្រាំងធារាសាស្ត្រទំនើប រួមទាំងប្រភេទហ្វ្រាំងឌីស(disc) និងហ្វ្រាំងស្គរ (drum) នៅក្នុងយានយន្តជំនាន់ថ្មីជាច្រើនប្រភេទ។

កម្រិតដំណើរការ និងអត្ថប្រយោជន៍

FMVSS 116 DOT-4, SAE J 1703, IS:8654-2001

- ភាពរាវល្អប្រសើរ ធានាបាននូវដំណើរការប្រកបដោយប្រសិទ្ធភាពនៅសីតុណ្ហភាពទាបខ្លាំង
- បង្កើនភាពធន់នឹងអុកស៊ីតកម្ម និងស្ថិរភាពកម្តៅ

- សមត្ថភាពរំអិលដ៏ល្អឥតខ្ចោះ ដើម្បីកាត់បន្ថយការកកិត និងការសឹក (wear) រវាងស្តុង និងស៊ីឡាំងនៅ ក្នុងប្រព័ន្ធហ្វ្រាំង

-ប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំណើម/ទឹក ធានាសុវត្ថិភាពប្រព័ន្ធហ្វ្រាំងក្នុងរយៈពេលវែង

- អាចប្រើប្រាស់បានយ៉ាងល្អជាមួយគ្រឿងបន្លាស់ប្រភេទកៅស៊ូ (elastomers) ដើម្បីការពារបញ្ហាជាមួយ ហ្គាសស្គីត (gaskets) និងស៊ីល (seals)

- ការពារការកើតច្រេះ និងការសឹកច្រេះក្នុងរយៈពេលវែង

- ចំណុចពុះខ្ពស់ ដើម្បីទប់ស្កាត់បញ្ហាកើតមានចំហាយក្នុងប្រព័ន្ធហ្វ្រាំង (vapor lock) សូម្បីតែនៅសីតុណ្ហភាពប្រតិបត្តិការខ្ពស់

លក្ខណៈរូបវន្តទូទៅ

កម្រិតFMVSS Grade	DOT 4
ដង់ស៊ីតេនៅ 15°C , kg/cu m	1.045
ភាពស្អិតKinematic Viscosity នៅ 40°C , cSt	1300
ភាពស្អិតKinematic Viscosity នៅ 100°C , cSt	2.2
ចំណុចពុះ Equilibrium Reflex Boiling Point (ERBP), ^{0}C	225
ចំណុចពុះពេលមានសំណើម Wet ERBP, ^{0}C	160
កម្រិត pH Value	8.6

ប្រេងអ៊ីដ្រូលីក (Hydraulic Oil)

Pure Gold

ផលិតផល

ប្រេងអ៊ីដ្រូលីក AW

កម្រិត (Grade)

VG 10, 15, 22, 32, 46, 68, 100

សេចក្តីណែនាំ

ផលិតឡើងពីប្រេងមូលដ្ឋាន (base stocks) ដែលបានចម្រាញ់យ៉ាងល្អិតល្អន់ និងមានសន្ទស្សន៍ viscosity ខ្ពស់ ព្រមទាំងផ្សំជាមួយសារធាតុបន្ថែមដែលត្រូវបានជ្រើសរើសយ៉ាងពិសេស ដើម្បីការពារការកត់ស៊ី(anti-oxidant) ការច្រេះ (anti-corrosion) ការសឹក (anti-wear) ស្នឹម (anti-rust) និងការបង្កើតពពុះ (anti-foam)។ ប្រេងទាំងនេះអាចទ្រាំទ្រនឹងសម្ពាធខ្ពស់ខ្លាំងរបស់ប្រព័ន្ធ និងល្បឿនខ្ពស់របស់ម៉ាស៊ីនបូម (pump) ហើយអាចប្រើប្រាស់បានយ៉ាងល្អជាមួយគ្រឿងបន្លាស់ប្រភេទ seals ដែលប្រើជាទូទៅនៅក្នុងប្រព័ន្ធអ៊ីដ្រូលីក។

ការប្រើប្រាស់

ត្រូវបានណែនាំឱ្យប្រើប្រាស់សម្រាប់ប្រព័ន្ធអ៊ីដ្រូលីក និងប្រព័ន្ធចរន្តប្រេង(circulation systems) ក្នុងវិស័យឧស្សាហកម្មជាច្រើនប្រភេទ ដែលទាមទារឱ្យមានអាយុកាលប្រើប្រាស់បានយូរ។

កម្រិតសមត្ថភាព និងអត្ថប្រយោជន៍

បំពេញតាមស្តង់ដារ Denison HF-0 (រួមទាំងT6C-020ទាំងលក្ខខណ្ឌស្ងួត និងសើម), U.S. Steel 127/136, Vickers M2950-S (គ្រឿងចក្រចល័ត), DIN 51524 ផ្នែកទី2, Vickers 1-286-S(គ្រឿងចក្រឧស្សាហកម្ម), GM LS-2, Cincinnati Machine P-68, P-70, Bosch Rexroth, JCMAS HK

- ពន្យារអាយុកាលប្រើប្រាស់របស់ប្រេង

-ស្ថិរភាពកម្តៅ និងប្រព័ន្ធធារាសាស្ត្រដ៏ល្អប្រសើរ

-សមត្ថភាពបំបែកទឹកចេញពីប្រេង (demulsibility) និងសមត្ថភាពបញ្ចេញខ្យល់បានយ៉ាងល្អ

-សមត្ថភាពឆ្លងកាត់តម្រង (filterability) និងស្ថិរភាពធន់នឹងកម្លាំងកាត់ (shear stability) បានយ៉ាងល្អ

-ប្រសិទ្ធភាពខ្ពស់ក្នុងការការពារការសឹក ការច្រេះ និងការកើតស្នឹម

លក្ខណៈរូបវន្តទូទៅ

កម្រិតISO Viscosity HLP	10	15	22	32	37	46	68	100
ដង់ស៊ីតេនៅសីតុណ្ហភាព15°C, kg/cu m	0.859	0.861	0.866	0.874	0.875	0.879	0.881	0.886
Kinematic Viscosity @ 40°C,cSt	10	15	22	32	37	46	68	100
Kinematic Viscosity@100°C, cSt	2.67	3.4	4.3	5.4	5.9	6.7	8.6	11.2
សន្ទស្សន៍ Viscosity Index	102	102	102	101	101	98	97	98
ចំណុចឆេះ Flash Point, COC, °C	160	166	204	210	212	216	220	226
ចំណុចកក Pour Point, °C	-30	-27	-21	-18	-18	-15	-12	-12
ការធ្វើតេស្តម៉ាស៊ីនបូម Pump Tests	Pass	Pass	Pass	Pass	Pass	Pass	Pass	Pass
ការធ្វើតេស្តភាពសឹកដោយប្រើបាល់ ៤ គ្រាប់ (15kg/80^{0}C/600rpm/2hrs)	Pass	Pass	Pass	Pass	Pass	Pass	Pass	Pass

ប្រេងអ៊ីដ្រូលីក (Hydraulic Oil)

ផលិតផល

ប្រេងអ៊ីដ្រូលីក HLP

កម្រិត (Grade)

VG 15, 22, 32, 46, 68, 100

សេចក្តីណែនាំ

គឺជាប្រេងអ៊ីដ្រូលីកគុណភាពខ្ពស់ ដែលមានលក្ខណៈសម្បត្តិពិសេសក្នុងការការពារការសឹក (anti-wear) សម្រាប់ប្រតិបត្តិការធ្ងន់ មានស្ថិរភាពកម្តៅដ៏ល្អប្រសើរ និងទទួលបានកម្រិតវាយតម្លៃ FZG ខ្ពស់។ ប្រេងទាំងនេះមានភាពឆបគ្នាបានយ៉ាងល្អជាមួយគ្រឿងបន្លាស់ប្រភេទ Seal ដែលប្រើប្រាស់ជាទូទៅក្នុងប្រព័ន្ធអ៊ីដ្រូលីក និងមានស្ថិរភាពពិសេសប្រឆាំងនឹងប្រតិកម្មជាមួយទឹក (hydrolytic stability)។

ការប្រើប្រាស់

ត្រូវបានណែនាំឱ្យប្រើសម្រាប់ប្រព័ន្ធអេឡិចត្រូ-អ៊ីដ្រូលីក (electro-hydraulic) ឬប្រព័ន្ធដែលដំណើរការដោយប្រព័ន្ធគ្រប់គ្រងលេខ (numerically controlled systems) ដែលមានប្រសិទ្ធភាពខ្ពស់។ ប្រេងទាំងនេះក៏អាច ប្រើជាប្រេងសម្រាប់ម៉ាស៊ីនបង្ហាប់ខ្យល់ប្រភេទ Screw (screw compressor) ផងដែរ។

កម្រិតសមត្ថភាព និងអត្ថប្រយោជន៍

IS: 10522:1983 [បញ្ឈប់ឡើងវិញនៅខែវិច្ឆិកា ឆ្នាំ១៩៩៨], DIN 51524 ផ្នែកទី ២, Denison HF-0 (រួមទាំង T6C-020 ក្នុងលក្ខខណ្ឌស្តង់ដារ និងសើម), U.S. Steel 127/136, Vickers M-2950-S (គ្រឿងចក្រចល័ត), DIN 51524 ផ្នែកទី ២, Vickers 1-286-S (គ្រឿងចក្រឧស្សាហកម្ម), GM LS-2, Cincinnati Machine P-68, P-70, Bosch Rexroth, JCMAS HK

- ពន្យារអាយុកាលប្រើប្រាស់របស់ប្រេង
- ស្ថិរភាពកម្តៅ និងប្រព័ន្ធធារាសាស្ត្រដ៏ល្អប្រសើរ
- សមត្ថភាពបំបែកទឹកចេញពីប្រេង (demulsibility) និងសមត្ថភាពបញ្ចេញពពុះខ្យល់បានយ៉ាងល្អ
- សមត្ថភាពឆ្លងកាត់តម្រង (filterability) និងស្ថិរភាពធន់នឹងកម្លាំងកាត់ (shear stability) បានយ៉ាងល្អ

- ប្រសិទ្ធភាពខ្ពស់ក្នុងការការពារការសឹក ការច្រេះ និងស្នឹម
- ភាពឆបគ្នាបានល្អប្រសើរជាមួយគ្រឿងបន្ទាស់ប្រភេទស៊ាល (seals) និងលោហៈទន់
- លក្ខណៈសម្បត្តិទាក់ទងនឹងកម្លាំងកកិតត្រូវបានកែលម្អ ដែលជួយកាត់បន្ថយសីតុណ្ហភាពប្រតិបត្តិការ

លក្ខណៈសម្បត្តិរបរន្តទូទៅ

កម្រិតISO Viscosity Grade-HLP	15	22	32	46	68	100
ដង់ស៊ីតេនៅសីតុណ្ហភាពនៅ15°C, kg/cu m	0.861	0.866	0.874	0.879	0.881	0.886
Kinematic Viscosity នៅ 40°C,cSt	15	22	32	46	68	100
Kinematic Viscosityនៅ100°C, cSt	3.8	4.9	6.4	8.2	10.9	14.7
សន្ទស្សន៍ Viscosity Index	150	150	150	150	150	150
ចំណុចឆេះ Flash Point, COC, °C	166	184	190	196	220	206
ចំណុចចាប់ផ្តើមហូរ Pour Point, °C	-39	-39	-30	-27	-24	-21
ការធ្វើតេស្តម៉ាស៊ីនបូម Pump Tests	Pass	Pass	Pass	Pass	Pass	Pass
ការធ្វើតេស្តភាពសឹកដោយប្រើបាល់៤គ្រាប់(15kg/80^{0}C/600rpm/ម៉ោង)	Pass	Pass	Pass	Pass	Pass	Pass

ប្រេងអ៊ីដ្រូលីក (Hydraulic Oil)

ផលិតផល

ប្រេងអ៊ីដ្រូលីកប្រភេទ HVI (High Viscosity Index)

កម្រិត (Grade)

Pure Gold

VG 32, 46, 68 និង 100

សេចក្តីណែនាំ

គឺជាប្រេងអ៊ីដ្រូលីកគុណភាពខ្ពស់ដែលមានសន្ទស្សន៍ (viscosity index) ខ្ពស់ មានស្ថិរភាពល្អប្រសើរប្រឆាំង និង ការកាត់ផ្តាច់ម៉ូលេគុល (shear stability) និងអាចទប់ទល់នឹងកម្រិតសីតុណ្ហភាពបានយ៉ាងទូលំទូលាយ។ ប្រេង ទាំងនេះមានផ្ទុកសារធាតុបន្ថែមពិសេសដែលជួយកាត់បន្ថយការសឹករិចរិល ការកើតច្រែះ ការកត់ស៊ី (oxidation) ជាដើម ព្រមទាំងផ្តល់នូវស្ថិរភាពល្អប្រឆាំងនឹងប្រតិកម្មជាមួយទឹក (hydrolytic stability) និងមាន លក្ខណៈសម្បត្តិល្អក្នុងការបំបែកទឹកចេញពីប្រេង។ លើសពីនេះ វាមានសមត្ថភាពល្អក្នុងការទប់ស្កាត់ការបង្កើត ពពុះនិងជួយបញ្ចេញខ្យល់ចេញពីប្រេងដែលធានាបាននូវប្រតិបត្តិការរលូននិងប្រសិទ្ធភាពខ្ពស់នៃប្រព័ន្ធ។ ប្រេង ទាំងនេះក៏មានភាពឆបគ្នាបានយ៉ាងល្អជាមួយគ្រឿងបន្លាស់ប្រភេទស៊ីល (seals) ដែលប្រើប្រាស់ជាទូទៅនៅក្នុង ប្រព័ន្ធធារាសាស្ត្រ។

ការប្រើប្រាស់

ត្រូវបានណែនាំជាចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រឿងចក្រធារាសាស្ត្រប្រភេទអេស្កាវ៉ាទ័រ (excavators) ដូចជាម៉ាក Tata-Hitachi, L & T, Komatsu ជាដើម ហើយក៏អាចប្រើប្រាស់សម្រាប់កម្មវិធីឧស្សាហកម្មផ្សេងៗទៀតដែលសម ស្របផងដែរ។

កម្រិតសមត្ថភាព និងអត្ថប្រយោជន៍

អនុលោមតាមស្តង់ដារ៖ DIN 51524 ផ្នែកទី II, Denison HF-0 (រួមទាំងការធ្វើតេស្ត T6C-020 ក្នុងលក្ខខណ្ឌស្ងួត និងសើម), U.S. Steel 127/136, Vickers M-2950-S (សម្រាប់គ្រឿងចក្រចល័ត), Vickers 1-286S (សម្រាប់ គ្រឿងចក្រឧស្សាហកម្ម), GM LS-2, Cincinnati Machine P-68, P-69 និង P-70, Bosch Rexroth, និងJCMAS HK។

-មានស្ថិរភាពកម្តៅ និងស្ថិរភាពធារាសាស្ត្រល្អប្រសើរ

- មានសមត្ថភាពបំបែកទឹកចេញពីប្រេង និងបញ្ចេញពពុះខ្យល់បានយ៉ាងល្អ
- អាចឆ្លងកាត់តម្រងបានយ៉ាងល្អ និងមានស្ថិរភាពធន់នឹងកម្លាំងកាត់ (shear stability) ល្អ
- មានភាពធន់ខ្ពស់បំផុតប្រឆាំងនឹងការកត់ស៊ី និងការបង្កើតពពុះ
- មានប្រសិទ្ធភាពខ្ពស់ក្នុងការទប់ស្កាត់ការសឹករិចរិល ការច្រេះ និងស្នាមច្រេះដែក
- អាចប្រើប្រាស់បានយ៉ាងល្អជាមួយគ្រឿងបន្លាស់ប្រភេទស៊ីល (seals) និងលោហៈទន់ផ្សេងៗ។

លក្ខណៈរូបវន្តទូទៅ៖

កម្រិតតាមស្តង់ដារISO Viscosity Grade-HVLP	32	46	68	100
ដង់ស៊ីតេនៅសីតុណ្ហភាព 15°C, kg/cu m	0.874	0.879	0.881	0.886
Kinematic Viscosity នៅសីតុណ្ហភាព 40°C,cSt	32	46	68	100
Kinematic Viscosity នៅសីតុណ្ហភាព100°C, cSt	6.4	8.2	10.9	14.7
សន្ទស្សន៍ Viscosity Index	150	150	150	150
ចំណុចឆេះ Flash Point, COC , °C	190	210	200	210
ចំណុចត្រជាក់រឹង Pour Point, °C	-30	-27	-24	-21
ការធ្វើតេស្តលើម៉ាស៊ីនបូម Pump Tests	Pass	Pass	Pass	Pass
ការធ្វើតេស្តការសឹករិចរិលប្រភេទ4-Ball Wear Test(15kg/80^{0}C/600rpm/2 ម៉ោង)	Pass	Pass	Pass	Pass

ប្រេងអ៊ីដ្រូលីក (Hydraulic Oil)

Pure Gold

ផលិតផល

ប្រេងអ៊ីដ្រូលីក ប្រភេទ RO

